ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន និងឯកសារ

# សេចក្តីជូនព័ត៌មាន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកប្រចាំឆ្នាំ២០១៧ ក្រោមប្រធានបទ «ការរៀបចំប្រព័ន្ធពិភពលោកប្រឈមមុខនឹងភាពមិនច្បាស់លាស់នៃនយោបាយ និងសេដ្ឋកិច្ច» ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ១៧ ដល់ ២០ ខែ មករា ឆ្នាំ ២០១៧ នៅទីក្រុងដាវ៉ូស-ក្លូស្ទ័រ ប្រទេសស្វីស តបតាមការអញ្ជើញរបស់លោកសាស្ត្រាចារ្យ ក្លូស ស្វាប់ (Klaus Schwab) ស្ថាបនិក និងជាប្រធានប្រតិបត្តិវេទិកាសេដ្ឋកិច្ចពិភពលោក។

នៅក្នុងវេទិកានេះ សម្តេចតេជោ ហ៊ុន សែន នឹងចូលរួមក្នុងកិច្ចប្រជុំនានា ដែលមានប្រធានបទដូចតទៅ:

១- ការដាក់ដំណើរការគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ ការបើកចំហរកិច្ចសហប្រតិបត្តិការរដ្ឋាភិបាល-ឯកជន
២- ចក្ខុវិស័យថ្មីមួយសម្រាប់វិស័យកសិកម្មៈ ការកសាង និងការពង្រឹងភាពជាដៃគូពហុភាគីពាក់ព័ន្ធ
៣- ការប្រជុំពហុភាគីរវាងសម្តេចតេជោនាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំពិភពលោក
៤- ការប្រជុំក្រៅផ្លូវការនៃថ្នាក់ដឹកនាំសេដ្ឋកិច្ចពិភពលោកៈ ការឆ្លើយតប និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ នៅក្នុងពហុភាគីប៉ូលនៅក្នុងពិភពលោក
៥- អាស៊ានក្នុងរយៈពេល៥០ឆ្នាំៈ តើអាស៊ានមានដំណើរទៅមុខទៀតយ៉ាងដូចម្តេច?
៦- ការពិភាក្សាឯកជន នៃថ្នាក់ដឹកនាំសេដ្ឋកិច្ចពិភពលោក ស្តីពីការស្រាវជ្រាវឲ្យមានដំណើរការដោយរលូននៃបដិវត្តឧស្សាហកម្មលើកទី៤
៧- វិថីអាស៊ាន រីផ្លូវហាយវេក្នុងពិភពលោកពោរពេញដោយភាពបែកបាក់ និង
៨- ការបង្ហាញពីការផលិតៈ តើអាស៊ានជាសហគមន៍មួយហើយរឺនៅ?

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

អាស្រ័យដោយកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះសម្រាប់វេទិកាសេដ្ឋកិច្ចពិភពលោក ស្តីពីអាស៊ាន នៅឆ្នាំនេះ សម្តេចតេជោ ហ៊ុន សែន នឹងឆ្លៀតយកឱកាសវេទិកាសេដ្ឋកិច្ចពិភពលោកនេះ ដើម្បីបង្ហាញពីអាស៊ាន និងផ្សព្វផ្សាយពីប្រទេសកម្ពុជា នៅក្នុងកម្មវិធីពិសេសមួយដែលមានចំណងជើង "កម្ពុជា៖ ផ្កាយកំពុងរះរបស់អាស៊ាន" ។ កម្ពុជាក៏នឹងបង្ហាញជូននូវវីដេអូខ្លីមួយ ស្តីពីការរៀបចំរបស់កម្ពុជាសម្រាប់វេទិកាសេដ្ឋកិច្ចពិភពលោក ស្តីពីអាស៊ាន ផងដែរ។

គណៈប្រតិភូអមដំណើរសម្តេចតេជោ ហ៊ុន សែន រួមមាន៖

១- ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

២- ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣- ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសមាជិកនៃរាជរដ្ឋាភិបាលកម្ពុជាមួយចំនួនទៀត។

កិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកប្រចាំឆ្នាំ គឺជាការជួបប្រជុំថ្នាក់ដឹកនាំពិភពលោកកំរិតខ្ពស់បំផុត ពីរដ្ឋាភិបាល អ្នកជំនួញ អ្នកស្រាវជ្រាវ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ដែលប្រព្រឹត្តទៅនៅរៀងរាល់ដើមឆ្នាំ ដើម្បីកំណត់របៀបវារៈ ពិភពលោក តំបន់ និងឧស្សាហកម្ម។

ក្នុងឱកាសអញ្ជើញចូលរួមវេទិកានេះ សម្តេចតេជោ ហ៊ុន សែន នឹងជួបពិភាក្សាទ្វេភាគីជាមួយលោកសាស្ត្រាចារ្យ ក្លូស ស្វាប់ ស្ថាបនិក និងជាប្រធានប្រតិបត្តិវេទិកាសេដ្ឋកិច្ចពិភពលោក ព្រមទាំងជាមួយបណ្តាថ្នាក់ដឹកនាំនៃប្រទេសមួយចំនួន ផងដែរ។៸

ភ្នំពេញ, ថ្ងៃទី១២ ខែ មករា ឆ្នាំ ២០១៧